SILAKA

# ឯកសារពិស្ដារ

## ម៉ូឌុល ៣

# ការចូលរួមរបស់ពលរដ្ឋ



# ម៉ូឌុល ៣

# ការចូលរួមរបស់ពលរដ្ឋ

មាតិកា ទំព័រ


| | | |
|---|---|---|
| ១- | ការយល់ដឹងអំពីសង្គមស៊ីវិល | ១ |
| ២- | ការពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ | ៣ |
| ៣- | ភាពជាពលរដ្ឋ | ៦ |
| ៤- | យែនឌ័រ និងអភិបាលកិច្ច : ការផ្តល់អំណាចដឹកនាំដល់ស្ត្រី | ៧ |


## ១- ការយល់ដឹងអំពីសង្គមស៊ីវិល

"**សង្គមស៊ីវិល** " បានចាប់កំណើតក្នុងបស្ចឹមប្រទេស (លោកខាងលិច)នាសតវត្សរ៏ទី ១៧ ក្នុងយុគសម័យ Renaissance (សម័យទំនើប)។ ចាប់តាំងពីពេលនោះមកទស្សនទាន "**សង្គមស៊ីវិល** " ត្រូវបានគេឱ្យនិយមន័យ និងមានការយល់ឃើញខុសៗគ្នាពីជំនាន់មួយទៅជំនាន់មួយ។

ការចាប់អារម្មណ៍លើសង្គមស៊ីវិលនាសម័យទំនើបចាប់ផ្តើមផុសផុលឡើង ក្រោយការដួលរលំនៃរបបកុម្មុយនិស្តនៅអឺរ៉ុបខាងកើតនិងកណ្តាល។ ទស្សនទាននិងប្រតិបត្តិការនាទសវត្សរ៏កន្លងមកចាប់ផ្តើមមានសារសំខាន់ក្នុងអំឡុងពេលមានការផ្លាស់ប្តូរតួនាទីដ៏ចម្បងរបស់រដ្ឋនិងសេដ្ឋកិច្ចទីផ្សារ។

ការយល់ឃើញលើកដំបូងកើតចេញពីប្រពៃណីអង់គ្លូ-អាមេរិកាំង និងស្នាដៃរបស់សង្គមវិទូTocqueville។ តាមការយល់ឃើញនេះសង្គមស៊ីវិលត្រូវបានគេមើលឃើញថាជាអន្តរការីនៅចន្លោះបុគ្គលនិងគ្រួសារ ឬម្យ៉ាងវិញទៀតរវាងបុគ្គលនិងស្ថាប័នរដ្ឋ។ ទោះបីជាស្ថាបន័រដ្ឋចាប់កំណើតមកជាស្ថាប័នប្រជាធិបតេយ្យក៏ដោយស្ថាបន័រដ្ឋចាប់ផ្តើមមានឥទ្ធិពលលើគ្រប់វិស័យ ដែលពលរដ្ឋមានទំនាក់ទំនងជាមួយរដ្ឋដូចជា សុខភាព ការអប់រំ និងសេវាសាធារណ:។

អត្ថន័យទីពីរនៃសង្គមស៊ីវិល កើតចេញពីការប្រឈមមុខរវាងប្រជាពលរដ្ឋ និងរបបកុម្មុយនីស្តនៅអឺរ៉ុបខាងកើត។ ពលរដ្ឋចាប់ផ្តើមប្រឆាំងនឹងអំណាចផ្តាច់ការនៅអឺរ៉ុបខាងកើតនិងអតីតសហភាពសូវៀត ព្រមទាំងអំណាចផ្តាច់ការយោធានិយមនៅអាមេរិកឡាទីន ហ្វីលីពីន និងអាហ្វ្រិកខាងត្បូង។ ចលនាទាំង នេះបាននាំលិទ្ធិប្រជាធិបតេយ្យ និងមូលដ្ឋានសេរីភាពដល់ពលរដ្ឋ។ ក្នុងទម្រង់នេះសង្គមស៊ីវិលចាប់ផ្តើមធ្វើឱ្យមានសមភាពជាមួយនិងដំណើរការលិទ្ធិប្រជាធិបតេយ្យក្នុងរចនាសម្ព័ន្ធ និងប្រព័ន្ធនយោបាយនានា។

ការយល់ឃើញទីបី មានឫសគល់ចេញពីការទទួលយកទីផ្សារសេរីជាសកល និងសហគ្រាសឯកជនជាម៉ាស៊ីនអភិវឌ្ឍសេដ្ឋកិច្ច ។ ការផ្លាស់ប្តូរតួនាទីនិងការចូលរួមចំណែកអភិវឌ្ឍសង្គមរបស់ ផ្នែកសាធារណៈ (រដ្ឋនិងស្ថាបន័រដ្ឋ) និងផ្នែកឯកជន (សហគ្រាសដើម្បីប្រាក់ចំណេញ)។

សង្គមស៊ីវិលត្រូវបានកំណត់ន័យថា ជាការរួមគ្នានៃបុគ្គលនិងគំនិតផ្តួចផ្តើមរួមគ្នាដើម្បី សំរេចបានសមិទ្ធិផលសាធារណៈ។ និយមន័យសង្គមស៊ីវិលទទួលស្គាល់វត្តមាននៃគំនិតផ្តួចផ្តើមបុគ្គលដែលមាន ក្នុងវប្បធម៌ខុសៗគ្នា។ ទោះបីជាសកម្មភាពបុគ្គលមានដែនកំណត់ជាមួយទំហំតិចតួចយ៉ាងណាក្តី ក៏បានចូលរួមជាវិភាគទានដល់ការរីកចំរើនសង្គមទាំងមូល។ ទស្សនទានសង្គមស៊ីវិលត្រូវបានពង្រឹងតាមរយៈសាសនា ព្រមទាំងជំនឿប្រពៃណីផ្សេងៗក្នុងសង្គមខុសៗគ្នា និងសម័យកាលប្រវត្តិសាស្ត្រផ្សេងៗគ្នា ។

និយមន័យនេះធ្វើឱ្យយើងយល់អត្ថន័យនិងការបកស្រាយកិច្ចការសាធារណៈ។ ជាប្រវត្តិសាស្ត្រកិច្ចការសាធារណៈស្ថិតក្រោមស្ថាប័នសាធារណៈ និយាយជារួមគឺស្ថាប័នរដ្ឋនិងការបង្កើតនយោបាយ។ ស្របពេលដែល ស្ថាប័នសាធារណៈមានការថយចុះ ការកើនឡើងនូវតម្រូវការនិងផលប្រយោជន៍ផ្សេងៗគ្នារបស់ប្រជាជន ការឆ្លើយតបនឹងកិច្ចការសាធារណៈលែងស្ថិតក្នុងដៃរបស់ស្ថាប័នរដ្ឋ/សាធារណៈទៀតហើយ។ ពលរដ្ឋក្នុងស្រទាប់ផ្សេងៗគ្នាបកស្រាយកិច្ចការសាធារណៈក៏ផ្សេងៗគ្នាដែរ។ ភាពខុសគ្នានេះក៏កើតមានតាំងពីតថភាពក្នុងស្រុកដល់ បញ្ហាពិភពលោក។

ភាពខុសគ្នាស្រឡះ បានបង្កើតព្រំដែននិងមុខងាររបស់រដ្ឋនិង សង្គមស៊ីវិល។ សូមកត់សម្គាល់ថា ពេលដែលសង្គមស៊ីវិលខំរក្សាស្វ័យភាពចេញពីរដ្ឋ ស្វ័យភាពនោះមិនមែនជាស្វយ័តភាពដាច់ខាតនោះទេ។ និយមន័យសង្គមស៊ីវិលរបស់យើងពុំគ្រាន់តែបញ្ចូលអង្គភាពផ្លូវការប៉ុណ្ណោះទេ ថែមទាំងអង្គភាពក្រៅផ្លូវការផងដែរ។ មានសមាគមបណ្តាញនិងសម្ពន្ធ័ភាពជាច្រើន ដែលមានកម្រិតនៃការចងក្រងបង្កើតឡើងខុសៗគ្នា ។ សង្គមស៊ីវិលមួយចំនួនខ្វះការរៀបចំទម្រង់អង្គភាព។

សង្គមស៊ីវិលជាច្រើនបានជួយអង្គភាពដទៃធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព តាមរយៈផ្តល់ការគាំទ្រ ដូចជាមូលនិធិសប្បុរសធម៌សមាជិក និងបណ្តាញអង្គភាព។ល។ អង្គការអន្តរការីទាំងនេះក៏ស្ថិតក្នុងអត្តន័យដ៏ទូលំទូលាយរបស់សង្គមស៊ីវិល។

**សេចក្តីសន្និដ្ឋាន**

ដោយប្រើប្រាស់ក្របខ័ណ្ឌការងារសមាគម ផែនដីសង្គមស៊ីវិល បង្ហាញអោយឃើញកិច្ចការសាធារណៈទាំងមូល។ ពីការបម្រើផលប្រយោជន៍របស់សហគមន៍ជាពិសេស ឬ ក៏ក្រុមដែលគេមិនអើពើរហូតដល់ក្រុមថ្នាក់កណ្តាល និងវរជន ដូចជា សមាគមផ្សេងៗដែលមានសមាសភាព រចនាសម្ព័ន្ធ និងកម្រិតនៃការបង្កើត ទំហំធនធាន និង គុណភាពនៃលទ្ធផល។ នេះជាផែនទី ណែនាំប្រភេទសមាគមន៍នាពេលបច្ចុប្បន្នបានយ៉ាងល្អបំផុត។

ទោះបីជាយ៉ាងណានេះក្តី ការចាត់ថ្នាក់ខាងលើនេះ មិនបានបញ្ចូលគំនិតបុគ្គលទេ ។ ផែនទីក៏មិនរាប់បញ្ចូលក្រុមបណ្តោះអាសន្នដូចជាគណៈកម្មាធិការជួយសង្គ្រោះទឹកជំនន់ ក្រុមដែលមានលក្ខណៈកូនកាត់មួយចំនួនក៏មិនមានក្នុងផែនទីនេះផងដែរ ។ ផែនទីក៏មិនបានកម្រិតស្វ័យភាពប្រសិទ្ធភាព ការចូលរួមដោយស្មគ្រ័ចិត្តនៅក្នុងសមាគម។ ក្រៅពីដែនកំណត់ទាំងនេះ ផែនទីសង្គមស៊ីវិលបានផ្តោតលើសារជាតិ និងកំរិតការចូលរួម ដោយស្មគ្រចិត្តក្នុងសមាគមដើម្បីទទួល បានផលប្រយោជន៍ពីកិច្ចការសាធារណៈ។

## ២ - ការពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ

អាស្រ័យលើបរិបទនៃសកម្មភាពគំរោង អន្តរាគមន៍នានាដើមដំបូងក្នុងការប្រមូលការចូលរួមពីប្រជាពលរដ្ឋអាចចាប់ផ្តើមជាមួយនឹងការលើកទឹកចិត្ត និងកំណត់គោលដៅទៅលើភាពដឹកនាំរបស់ស្ត្រី។ នៅក្នុងជំហានទី២ អន្តរាគមន៍គួរចាប់ផ្តើមធ្វើការជាមួយបុរស ជាពិសេសគឺយុវជន ក្នុងខណៈនោះក៏រក្សាខ្ជាប់នូវការផ្តោតយកចិត្តទុកដាក់លើការអភិវឌ្ឍន៍ភាពដឹកនាំរបស់ស្ត្រីដែរ។ ជាលទ្ធផល មានអង្គភាពសហគមន៍មួយចំនួនធំបានចូលរួមនៅក្នុងអន្តរគមន៍។

វិធីសាស្រ្តពហុមាត្រាក្នុងការកសាងសមត្ថភាពដល់តំណាងប្រជាពលរដ្ឋ និងសមូហភាពត្រូវបានគេប្រើប្រាស់ដើម្បី សម្រេចបានទិសដៅនានា។ ខាងក្រោមនេះគឺជាការពិពណ៌នាសង្ខេបនៃវិធីសាស្រ្តក្នុងការពង្រឹងសមត្ថភាពៈ

***(ក) ការរៀបចំឯកសារព័ត៌មានសម្រាប់ប្រជាសមូហភាព:*** មុននឹងចាប់ដៃធ្វើជាមួយអ្នកដឹកនាំប្រជាពលរដ្ឋ យើងត្រូវធ្វើផែនទីអំពីអង្គការមូលដ្ឋានដែលមានស្រាប់ ដើម្បីកំណត់អ្នកដឹកនាំប្រជាពលរដ្ឋដែលមានសក្ដានុពលសិន។ បន្ទាប់ពីមានព័ត៌មានហើយ យើងនឹងរកឱ្យឃើញប្រជាពលរដ្ឋខ្លះដែលសកម្មនៅក្នុងសហគមន៍ ដែលពាក់ពន្ធ័នឹងសកម្មភាពរួមគ្នា ឬអ្នកដែលនឹងក្លាយជាអ្នកចេះជួយយកអាសារដល់អ្នកជិតខាងតាមមធ្យោបាយនានា។ ពេលនោះសមាជិកក្នុងសហគមន៍ក៏ទទួលស្គាល់ចំពោះការរួមចំណែករបស់ពួកគេដែរ ។ កិច្ចខិតខំប្រឹងប្រែងនានាត្រូវបានធ្វើឡើង ដើម្បីទាក់ទងឱ្យប្រជាពលរដ្ឋទាំងនោះ ស្រាក់ដៃគ្នាធ្វើកម្មវិធីជុំវិញសមត្ថភាព ដែលពួកគេមានស្រាប់ ។

***(ខ) ការបណ្ដុះបណ្ដាលសម្រាប់ប្រជាសមូហភាព និងពលរដ្ឋជនបង្គោល :***
កម្មវិធីបណ្ដុះបណ្ដាលជាស៊េរីរយៈពេលខ្លី (ពី១ ទៅ៣ ថ្ងៃ) សំរាប់ប្រជាសមូហភាពនិងអ្នកដឹកនាំប្រជាពលរដ្ឋ ត្រូវបានរៀបចំឡើងស្ទើរតែនៅគ្រប់តំបន់ ។ គោលបំណងនៃកម្មវិធីបណ្ដុះបណ្ដាលនេះរាប់បញ្ចូល តាំងពីការកសាងទស្សនៈវិស័យ ស្ដីអំពីអភិបាលកិច្ចថ្នាក់មូលដ្ឋាន និងភាពជាពលរដ្ឋ ដើម្បីពង្រឹងជំនាញអំពីការគ្រប់គ្រងក្រុម ការធ្វើផែនការកំរិតមូលដ្ឋាន ការកៀគរ យុត្តិធម៌យេនឌ័រ។ល។

***(គ) ការប្រជុំជាទៀងទាត់ និងការគាំទ្រដំណើរការ :*** អន្ដរាគមន៍នេះតម្រូវឱ្យមានកិច្ចប្រជុំទៀងទាត់ និងការគាំទ្រដំណើរការចំពោះសមូហភាព និងការដឹកនាំរបស់គេ ។ នៅតំបន់ជាច្រើន ការប្រឹក្សាយោបល់ ការណែនាំ និងការគាំទ្រដល់បុគ្គលអ្នកដឹកនាំ បានបង្ហាញឱ្យឃើញថាមានសារៈប្រយោជន៍។ សមាជិកនៃប្រជាសមូហ ភាពត្រូវបានផ្ដល់នូវការគាំទ្រដែលជាទូទៅទាក់ទងនឹងតម្រូវការប្រចាំថ្ងៃរបស់ពួកគេ។

***(ឃ) ទស្សនកិច្ចសិក្សា :*** គោលបំណងនៃការរៀបចំទស្សនកិច្ចសិក្សា គឺដើម្បីសម្រួលការសិក្សាដល់អ្នកដឹកនាំប្រជាពលរដ្ឋលើគំនិតផ្ដួចផ្ដើមអភិវឌ្ឍន៍ផ្សេងៗដែលពួកគេអាចចម្លងយកបាន ។ មានតែបុគ្គលមួយចំនួនដែលត្រូវបានជ្រើសរើសប៉ុណ្ណោះ អាចចូលរួមក្នុងទស្សនកិច្ចសិក្សានោះបាន ដូច្នេះការខំប្រឹងប្រែងត្រូវបានធ្វើឡើង ដើម្បីឱ្យការសិក្សាដែលអ្នកដឹកនាំប្រជាពលរដ្ឋទទួលបាន អាចចែករំលែកទៅឱ្យសមាជិកផ្សេងទៀត នៃក្រុមសមូហភាព និងសហគមន៍ទូទៅ ។

### (ង) សិក្ខាសាលា/កិច្ចប្រជុំផ្ទាល់ជាមួយប្រជាពលរដ្ឋ:

លទ្ធផលរំពឹងទុកមួយនៃអន្តរាគមន៍ពង្រឹងប្រជាសមូហភាព និងការដឹកនាំប្រជាពលរដ្ឋ គឺដើម្បីជំរុញឱ្យមានទំនាក់ទំនងដ៏មានប្រសិទ្ធភាព រវាងប្រជាពលរដ្ឋ និងស្ថាប័នអភិ បាលនានា។ ក្នុងតំបន់ជាច្រើនកិច្ចប្រជុំផ្ទាល់ និងសិក្ខាសាលាផ្សេងៗបានបង្កភាពងាយស្រួល ក្នុងការផ្តួចផ្តើម ការសន្ទនារគ្នា។

**(ច) ការរៀបចំយុទ្ធនាការ :** ស៊េរីនៃយុទ្ធនាការត្រូវបានរៀបចំឡើងសំដៅលើរឿងជាក់លាក់ និងព័ត៍មានអំពីការ បោះឆ្នោត។ ចំរៀងប្រពៃណីរបាំ និងការសំដែងតាមផ្លូវត្រូវបានប្រើប្រាស់យ៉ាងច្រើនក្នុងយុទ្ធនាការទាំង នេះ។ កិច្ចខិតខំប្រឹងប្រែងត្រូវបានធ្វើឡើងដើម្បីកសាងភាពជាម្ចាស់ តាមរយៈការបង្កឱ្យប្រជាពលរដ្ឋជាប់ ពាក់ព័ន្ធ និងការដឹកនាំក្រុមចាប់ពីការធ្វើផែនការរហូតដល់ការអនុវត្តន៍យុទ្ធនាការទាំងនេះឡើង។

**(ឆ) ការសំរួលបណ្តាញនៃប្រជាសមូហភាព :** ការសំរួល និងជំរុញបណ្តាញនៃប្រជាសមូហភាពដោយផ្តោតសំខាន់លើស្ត្រី ជនភាគតិច និងក្រុមជនងាយរងគ្រោះនានា គឺជាទិសដៅច្បាស់លាស់មួយនៃអន្តរាគមន៍កសាងសង្គមស៊ីវិលនៅកំរិតថ្នាក់ក្រោមជាតិ ។

## ការជាប់ទាក់គ្នានៃការកសាងសមត្ថភាព

ការបន្តប្រើប្រាស់នៃវិធីសាស្ត្រកសាងសមត្ថភាពពហុមាត្រា និងអន្តរាគមន៍ជាច្រើនបានផ្តល់នូវលទ្ធផលល្អៗ សំរាប់អ្នកដឹកនាំប្រជាពលរដ្ឋធ្វើការរួមគ្នាដើម្បីចូលរួមសកម្មភាពសមូហភាពនិងបុគ្គលនៅកំរិតសហគមន៍។ ពួកគេអនុវត្តភារកិច្ចទាំងនេះដោយការស្ម័គ្រចិត្ត។ ការចាប់ដៃគ្នាចូលរួមបង្កកាន់តែខ្លាំងឡើងនូវការអភិវឌ្ឍន៍នៃការប្រទាក់ក្រឡាគ្នា ទូទៅ នៅក្នុងសហគមន៍ :

- សកម្មភាពផ្តើមធ្វើការងារជួយខ្លួនឯង
- ការចាប់ដៃគ្នាចូលរួមធ្វើផែនការពីក្រោមទៅលើនៅកំរិតមូលដ្ឋាន
- ការកៀគរនៅថ្នាក់ក្រោមជាតិ (ភូមិ ឃុំ/សង្កាត់ និងស្រុក/ខណ្ឌ...)
- ការចាប់ដៃគ្នាចូលរួមជាមួយមន្ទីរជំនាញដើម្បីទទួលបានសេវាកម្ម
- ការចាប់ដៃគ្នាចូលរួមជាមួយស្ថាប័នអភិបាលដើម្បីដោះស្រាយរឿងអយុត្តិធម៌សង្គម ឬការរើសអើងក្នុងសង្គម
- ការចូលរួមក្នុងការបោះឆ្នោតថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ ។

## ៣- ភាពជាពលរដ្ឋ

ពាក្យថា "**ភាពជាពលរដ្ឋ**" ត្រូវបានពិភាក្សា កំណត់អត្ថន័យ និងយល់ឃើញខុសៗពីគ្នានៅក្នុងសាវតានយោបាយ។ នៅក្នុងបរិបទបច្ចុប្បន្ន ប្រទេសភាពជាពលរដ្ឋសំដៅលើជំរើសបុគ្គល។ គេចាត់ទុកថាសកម្មភាពបុគ្គល "ប្រកបដោយហេតុផល" ដើម្បីបង្កើនផលប្រយោជន៍របស់គេនៅក្នុងសង្គម។ ការផ្តោតជាសំខាន់លើជំរើសរបស់បុគ្គល គឺផ្អែកលើសច្ចភាពដែលរដ្ឋនឹងផ្តល់ឱ្យនូវការការពារជាចាំបាច់ ហើយនឹងអនុញ្ញាតក្នុងការប្រើប្រាស់ជរើសទាំងនេះរបស់បុគ្គល។ ម្យ៉ាងវិញទៀតមិនត្រូវទទួលស្គាល់ថាជំរើសរបស់បុគ្គលត្រូវបានដាក់លក្ខណ្ឌកំរិតដោយវិសមភាពនៅក្នុងសង្គមនោះទេ។

**សិទ្ធិ** និង **កាតព្វកិច្ច** គឺជាស្នូលនៃភាពជាពលរដ្ឋ។ ភាពជាពលរដ្ឋដែលជា "**សិទ្ធិ**" ត្រូវបានគេយល់ថាជាស្ថានភាពផ្លូវការដែលអនុញ្ញាតិដោយរដ្ឋ។ បុគ្គលត្រូវទទួលបានសិទ្ធិជាក់លាក់ជាសកលដែលដាក់តំកល់នៅក្នុងច្បាប់។ ភាពជាពលរដ្ឋដែលជា "កាតព្វកិច្ច" ត្រូវបានគេយល់ថា ជាការចូលរួមដែលមានចរិតនយោបាយនៃប្រជាពលរដ្ឋទាំងអស់ដែលជាកាតព្វកិច្ច។

**សិទ្ធិ** ដែលគិតថា មានចរិតនយោបាយ (ឧ: សិទ្ធិបោះឆ្នោត សិទ្ធិបង្កើតសមាគម) សិទ្ធិស៊ីវិល (ឧ: សេរីភាពបញ្ចេញមតិ សេរីភាពរបស់ពលរដ្ឋ) សិទ្ធិសង្គម (ឧ: មិនរើសអើង វណ្ណៈ សាសនា ឬ ភេទ និងមានលទ្ធភាពស្មើគ្នាដើម្បីទទួលបានសេវាដូចជាសុខភាព ការអប់រំ ជាដើម) សិទ្ធិ សេដ្ឋកិច្ច (ការពារទ្រព្យធនឯកជន លទ្ធភាពស្មើគ្នាដើម្បីទទួលការងារនិងធនធានប្រកបរបរចិញ្ចឹមជីវិត) សិទ្ធិវប្បធម៌ (ការការពារនិងរក្សាវប្បធម៌បុរាណ)។ នេះជារឿងដែលជាជំរើសសំរាប់បុគ្គលដើម្បីទាមទារនិងប្រើប្រាស់ សិទ្ធិ។ ភាគខ្លះនៃសិទ្ធិបានកំណត់នៅក្នុងច្បាប់ តែខ្លះទៀតពុំបានកំណត់ឡើយ។ តួនាទីរបស់រដ្ឋគឺការពារប្រជាពលរដ្ឋក្នុងការប្រើប្រាស់សិទ្ធិរបស់គេ។ មានអំណះអំណាងជាច្រើនថាពុំទាន់គ្រប់គ្រាន់នៅឡើយទេ។ ការប្រើប្រាស់ជំរើសឬការទាមទារសិទ្ធិត្រូវការធនធាន អំណាច និងចំណេះដឹង។

ខណៈដែលភាពជាពលរដ្ឋដែលផ្តល់ឱ្យចំពោះមនុស្សម្នាក់ដោយរដ្ឋ ក្នុងរដ្ឋប្រជាធិតេយ្យ រដ្ឋទាញចេញនូវភាពស្របច្បាប់ពីប្រជាពលរដ្ឋ ដែលជាអ្នកអនុញ្ញាតដោយស្ម័គ្រចិត្តស្ថិតនៅក្នុងអភិបាលកិច្ចដោយតំណាងដែលជាប់ឆ្នោត ហើយប្រសិនបើប្រជាពលរដ្ឋរួមគ្នាបដិសេធផ្តល់ភាពស្របច្បាប់ រដ្ឋនឹងបាត់បង់អត្តសញ្ញាណរបស់ខ្លួន។ ដូច្នេះគឺមានទំនាក់ទំនងមួយរវាងប្រជាពលរដ្ឋហើយនឹងរដ្ឋ។

ពលរដ្ឋម្នាក់គឺអាចចាត់ទុកថា ជាមនុស្សម្នាក់ដែលទទួលដោយពេញចិត្តនូវសិទ្ធិសង្គម សិទ្ធិនយោបាយ សិទ្ធិស៊ីវិល សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិវប្បធម៌ ជាមនុស្សនៃផ្នែករបស់ជាតិ និងសង្គម ព្រមទាំងជាអ្នកមានសិទ្ធិនិងកតព្វកិច្ចច្បាស់លាស់។ ពលរដ្ឋសកម្មម្នាក់ត្រូវយល់ដឹងអំពីការពិត និងមានឆន្ទៈធ្វើការងារ

ដើម្បីផ្លាស់ប្តូរការពិតឱ្យកាន់តែប្រសើរឡើង ខិតខំដើម្បីសមិទ្ធិផលរួមសាធារណៈ ហើយនឹងការប្រឹងប្រែងនៅក្នុងសហគមន៍របស់ខ្លួន។

## ៤- យេនឌ័រ និងអភិបាលកិច្ច : ការផ្តល់អំណាចដឹកនាំដល់ស្ត្រី

### តើយេនឌ័រជាអ្វី?

*យេនឌ័រ* គឺសំដៅលើតួនាទី ឥរិយាបថ ដែលសង្គមរំពឹងថា ស្ត្រីនិងបុរសគួរប្រព្រឹត្ត។ ក្រសួងកិច្ចការនារីបានឱ្យនិយមន័យថា យេនឌ័រជាការយកចិត្តទុកដាក់ទៅលើរបៀបខុសៗគ្នា ដែលទំនាក់ទំនងរវាងបុរសនិងស្ត្រីមានឥទ្ធិពល ទៅលើព្រឹត្តិការណ៍ និងដំណើរការខាងសេដ្ឋកិច្ច នយោបាយ សង្គម ច្បាប់ និងវប្បធម៌ និងការទទួលផលប៉ះពាល់របស់បុរសនិងស្ត្រីពីព្រឹត្តិការណ៍ និងដំណើរការនោះ (សន្ទានុក្រមយេនឌ័រ របស់ MoWA ២០០៦ )។

សមភាពយេនឌ័រ គឺបន្ថែមលើអភិបាលកិច្ច។ ទាំងស្ត្រី និងបុរសមានសិទ្ធិស្មើគ្នាស្ថិតក្រោមច្បាប់ មាន ឱកាសស្មើគ្នារួមទាំងភាពស្មើគ្នាក្នុងការទទួលបានសមត្ថភាព និងធនធានផលិតផលផ្សេងៗទៀតដែល ជួយឱ្យមានឱកាសនិងភាពស្មើគ្នាក្នុងការបញ្ចេញសម្លេងដើម្បីជាប្រយោជន៍ និងចូលរួមចំណែកដល់ដំណើរការអភិវឌ្ឍ (ធនាគារពិភពលោកៈ២០០១)។ ការចូលរួមស្មើៗគ្នារបស់បុរសនិងស្ត្រីក្នុងការគ្រប់គ្រង គឺមានសារៈសំខាន់ខ្លាំងណាស់ចំពោះហេតុផលមួយចំនួនដូចខាងក្រោម :

- មានឥទ្ធិពលលើការបែងចែកធនធានដែលកម្រ
- លើកកម្ពស់ល័ក្ខខ័ណ្ឌរស់នៅ និងបង្កើនចំណាប់អារម្មណ៍របស់ស្ត្រី
- ផ្លាស់ប្តូរការផ្តោតកិច្ចការនយោបាយតបទៅតាមបញ្ហានានាដែលជះឥទ្ធិពលដល់គុណភាពនៃការរស់។

### យេនឌ័រ និងអភិបាលកិច្ច

យេនឌ័រ គឺជាកត្តាដ៏សំខាន់បំផុតមួយនៅក្នុងការចូលរួម និងការធ្វើជាតំណាងនៅក្នុងការធ្វើសេចក្តីសម្រេចជាសាធារណៈ។ ទាំងស្ត្រី និងបុរសត្រូវការចូលរួម និងមានភាពសកម្មក្នុងការធ្វើសេចក្តីសម្រេច និងចងក្រងគោលនយោបាយ។ ប្រទេសឯករាជ្យនីមួយៗនៅជុំវិញពិភពលោក ធានានូវសិទ្ធិរបស់ប្រជាជនគ្រប់រូបចំពោះសមធម៌នយោបាយ។ លក្ខណៈវិនិច្ឆ័យលើសមធម៌រវាងភេទផ្សេងៗ អាចធ្វើឱ្យស្ត្រីមានសិទ្ធិ ចូលរួម និងជាតំណាងនៅក្នុង ការធ្វើសេចក្តីសម្រេចផ្នែកនយោបាយតាមផ្លូវការដោយមិនមានការរើសអើង។ ប៉ុន្តែ

តើស្ត្រីពិតជាបានចូលរួមស្មើភាពគ្នាជាមួយបុរសនៅក្នុងក្រុមអ្នកធ្វើសេចក្តីសម្រេច និងក្រុមអ្នកបង្កើតគោលនយោបាយដែរទេ?

## កត្តារារាំងការចូលរួមរបស់ស្ត្រីនៅក្នុងការងារគ្រប់គ្រង

កត្តាចម្បងដែលរារាំងដល់ការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេច និងអភិបាលកិច្ចនោះគឺ *វិសមភាពទំនាក់ទំនងយែនឌ័រ*។ ទំនាក់ទំនងយែនឌ័រ និងបែងចែកអំណាចរវាងភេទទាំងពីរ ទាំងនៅក្នុង កិច្ចការឯកជន (ផ្ទាល់ខ្លួន) និងកិច្ចការសាធារណៈ គឺមានវិសមភាពយែនឌ័រ។

*ការបែងចែកឯកជន-សាធារណៈ* រវាងស្ត្រីនិងបុរស តែងតែបានរារាំងស្ត្រីមិនឱ្យធ្វើការចរចានៅក្នុងកិច្ចការសាធារណៈ។ កិច្ចការឯកជន (ផ្ទាល់) ពាក់ព័ន្ធនឹង គ្រួសារ ការងារបន្តពូជ និងភាពជាស្ត្រី ហើយកិច្ចការសាធារណៈ ពាក់ព័ន្ធនឹង អំណាចនយោបាយ ការធ្វើសេចក្តីសម្រេចជាសាធារណៈ ការងារ ផលិតកម្ម និងភាពជាបុរស។ ស្ត្រីត្រូវក្រុមបុរសរិះគន់ថា មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ឬគួរស្ថិតនៅក្រោមការគ្រប់គ្រងរបស់បុរស។

*ស្វ័យភាពរបស់ស្ត្រី* នៅក្នុងគ្រួសារឬផ្ទះ ក៏មានឥទ្ធិពលទៅលើលទ្ធភាព និងសមត្ថភាពរបស់ស្ត្រីក្នុងការចូលរួមអភិបាលកិច្ចដែរ។ សិទ្ធិអំណាចរបស់ស្ត្រីនៅក្នុងផ្ទះត្រូវបានរិតត្បិត ដោយសារការមិនដឹង និងមិនមានលទ្ធភាពគ្រប់គ្រងទ្រព្យសម្បត្តិ មិនមានស្វ័យភាពក្នុងការធ្វើសេចក្តីសម្រេច មិនសូវមានការឱ្យតម្លៃខ្លួនឯង មានចំណេះដឹងនិងការអប់រំទាប កំសាំងកាយសម្បទារមានកម្រិត និងមានអំណាចតិចតួចបើធៀបទៅនឹងបុរស។

ឋានានុក្រមទាក់ទងគ្នាផ្សេងៗទៀត ដូចជា *ឋានៈសង្គម វណ្ណៈ អំបូរពូជសាសន៍ សាសនា និងទីតាំងជនបទ/ទីក្រុង* បានបន្តធ្វើឱ្យមានវិសមភាពយែនឌ័រកាន់តែស្មុគស្មាញនៅក្នុងអភិបាលកិច្ច។

អវត្តមានស្ត្រីនៅក្នុងដំណើរការអភិវឌ្ឍ សបញ្ជាក់ឱ្យឃើញថា ដំណើរការធ្វើសេចក្តីសម្រេចជាសាធារណៈពិតជាមិនបានលើកឡើងនូវតម្រូវការជាយុទ្ធសាស្រ្តរបស់ស្ត្រី នៅក្នុងបរិបទនៃទំនាក់ ទំនងយែនឌ័រឡើយ។ *ប្រសិនបើលទ្ធផលនៃអភិបាលកិច្ចល្អដែលចង់បាន គឺជាសមភាពដែលអាចចែករំលែកបាន នោះសមភាពយែនឌ័រគួរតែឈរយ៉ាងខ្ពស់នៅលើរបៀបវារៈរបស់រដ្ឋាភិបាល*។ (Commonwealth Foundation: 2004)